**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ : ៩៣២ ... សហវ.ប្រក

**ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល**

រាជធានីភ្នំពេញ, ថ្ងៃទី០៧ ខែ វិច្ឆិកា ឆ្នាំ២០១០

# ប្រកាសអន្តរក្រសួង

## ស្តីពី

## ការកំណត់ស្វ័យសារខ្សាច់សំណង់ និងខ្សាច់ល្បាយតក់ នាំចេញក្រៅប្រទេស

*******

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល**

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៦/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០១/០៩ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ

-បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្ត

ទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៤ ស្តីពីការបំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

## សម្រេច

**ប្រការ១ :**

សម្បទានិកដែលបានទទួលសិទ្ធិធ្វើអាជីវកម្មខ្សាច់សំណង់ និងខ្សាច់ល្បាយភក់ សម្រាប់នាំចេញក្រៅប្រទេស ត្រូវបង់សួយសារជូនរដ្ឋ នូវអត្រា ០,៦ ដុល្លាអាមេរិក ក្នុងមួយម៉ែត្រគូប ។

**ប្រការ២ :**

គណៈកម្មការចំរុះ ដែលរួមមានតំណាងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអាជ្ញាធរដែនដីរួមជាមួយមន្ទីរជំនាញ (មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល និងមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ) ត្រូវចុះធ្វើការត្រួតពិនិត្យសកម្មភាពផលិតកម្ម អាជីវកម្ម និងមធ្យោបាយដឹកជញ្ជូនខ្សាច់សំណង់ និងខ្សាច់ល្បាយភក់ សម្រាប់នាំចេញក្រៅប្រទេសតាមការដ្ឋាននីមួយៗ ដើម្បីគណនាចំនួនទឹកប្រាក់សួយសារដែលអាជីវករត្រូវបង់ពិតប្រាកដចូលថវិការដ្ឋ ។

គណៈកម្មការនេះ នឹងត្រូវបង្កើតឡើងក្រោមប្រកាសរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល បន្ទាប់ពីប្រកាសអន្តរក្រសួងនេះចូលជាធរមាន ។

**ប្រការ៣ :**

សម្បទានិកត្រូវបង់សួយសារដូចមានចែងក្នុងប្រការ១ នៅរតនាគាររាជធានី-ខេត្ត ដែលការដ្ឋានផលិតកម្មអាជីវកម្មនោះស្ថិតនៅ ដោយផ្អែកតាមបញ្ជាចំណូល (សាលាកប័ត្របង់ចំណូល ) របស់មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលរាជធានី-ខេត្ត មុនពេលខ្សាច់សំណង់ និងខ្សាច់ល្បាយភក់ត្រូវបានដឹកចេញពីការដ្ឋាន ។ មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលត្រូវធ្វើរបាយការណ៍ស្តីពីសភាពការណ៍អនុវត្តកាតព្វកិច្ចចំណូលប្រចាំខែ ជូនក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (នាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ) ដោយថតចំលងភ្ជាប់មកជាមួយនូវសាលាកប័ត្របង់ចំណូលទាំងអស់ដែលអនុវត្តបាន ។

**ប្រការ៤ :**

ក្រៅពីការបង់សួយសារខាងលើ សម្បទានិកត្រូវបង់ពន្ធអាករពាក់ព័ន្ធផ្សេងទៀតតាមច្បាប់សារពើពន្ធ ដែលមានជាធរមាន ។

រាល់អត្រាសួយសារ ដែលបានកំណត់ក្នុងកិច្ចព្រមព្រៀងស្តីពីការធ្វើអាជីវកម្មខ្សាច់សំណង់ និងខ្សាច់ល្បាយភក់នាំចេញ រវាងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងសម្បទានិកកន្លងមកត្រូវចាត់ទុកជានិរាករណ៍ ។

អង្គភាពពាក់ព័ន្ធក្រោមចំណុះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ព្រមទាំងសម្បទានិកដូចក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសអន្តរក្រសួងនេះ ។

**ប្រការ៥ :**

ប្រកាសអន្តរក្រសួងនេះមានប្រសិទ្ធភាព និងចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។៚

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**គាត ឈន់**

**រដ្ឋមន្ត្រី**
**ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល**

**ស៊ុយ សែម**

**ចម្លងជូន :**

-ខុទ្ទកាល័យព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
-គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន
-គ្រប់រាជធានី-ខេត្ត
-ដូចប្រការ៤
-ឯកសារ-កាលប្បវត្តិ